សហគមន៍ខ្មែរកម្ពុជាក្រោម

KHMER KAMPUCHEA KROM COMMUNITY

LA COMMUNAUTÉ DU KHMER KAMPUCHEA KROM


លេខ..............................ស.ខ.ក.ក.

# សេចក្ដីអំពាវនាវ

សហគមន៍ខ្មែរកម្ពុជាក្រោម សូមលំអោនកាយក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមគោរពជម្រាបជូនបងប្អូនរួមឈាមខ្មែរទាំងអស់ ព្រះមេត្តានិងមេត្តាជ្រាបថា ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១២ ជាខួបគម្រប់៦៣ឆ្នាំ(០៤-៦-១៩៤៩ ដល់ ០៤-៦-២០១២) នៃប្រវត្តិសាស្ត្រដ៏ឈឺចាប់បំផុតរបស់ប្រជាជាតិខ្មែរ ដែលអាណានិគមបារាំងបានកាត់ទឹកដីខ្មែរកម្ពុជាក្រោមប្រគល់ឲ្យអាណានិគមវៀតណាម។ ចាប់ពីពេលនោះមក បងប្អូនរួមឈាមខ្មែរនៅទីនោះ បានក្លាយជាជនជាតិភាគតិចនៅលើទឹកដីកំណើតរបស់ខ្លួន ហើយការតស៊ូដ៏ស្វិតស្វាញ ដោយបានលះបង់សាច់ស្រស់ឈាមស្រស់នៃខេមរកុលបុត្រកុលធីតាក្នុងការប្រយុទ្ធ ដើម្បីភាពគង់វង្សពូជសាសន៍ សាសនា សិល្បៈ វប្បធម៌ អក្សរសាស្ត្រនិងទំនៀមទំលាប់ខ្មែរដ៏ល្អផូរផង់ បានចាប់ផ្ដើមឡើងឥតឈប់ឈររហូតមកដល់សព្វថ្ងៃ។

ដើម្បីសម្ដែងនូវគារវកិច្ច និងកតញ្ញូតាធម៌ ចំពោះវីរភាពដ៏អង់អាចក្លាហាននៃបុព្វបុរសខ្មែរស្នេហាជាតិ សហគមន៍ខ្មែរកម្ពុជាក្រោមនៅជុំវិញពិភពលោក តែងតែប្រារព្ធពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន ១៩៤៩អង្គ ចាប់ពីឆ្នាំ២០០០ជារៀងរាល់ឆ្នាំរហូតមក ដើម្បីឧទ្ទិសកុសលប្រគេន ថ្វាយ និងជូនព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ព្រះវីរព្រះមហាក្សត្រ និងវីរបុរស វីរនារី វីរយុទ្ធជន វីរ-យុទ្ធនារីខ្មែរស្នេហាជាតិទាំងនោះ មិនដែលខកខានម្ដងណាឡើយ។ ជាមួយគ្នានិងការរៀបពិធីនេះដែរ អាជ្ញាធរខ្មែរតែងតែរាំងមិនអនុញ្ញាតឲ្យយើងរៀបចំជាទ្រង់ទ្រាយធំនៅទីសាធារណៈទេ ហើយបានដាក់កម្លាំងនគរបាលនិងនគរបាលយោធាបង្ក្រាបយើងថែមទៀតផង។ ប៉ុន្តែដោយការប្ដេជ្ញាចិត្ត និង ការសាមគ្គីគ្នារបស់ព្រះសង្ឃ និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ព្រមទាំងមហិទ្ធិឫទ្ធិបារមីនៃវីរបុរសខ្មែរស្នេហាជាតិ បានជួយជំរុញឲ្យសហគមន៍ខ្មែរកម្ពុជាក្រោមរៀបចំពិធីជាប្រវត្តិសាស្ត្រនេះបានប្រព្រឹត្តទៅដោយជោគជ័យជារៀងរាល់ឆ្នាំ។

សេចក្ដីដូចបានប្រគេននិងជម្រាបជូនខាងលើ សហគមន៍ខ្មែរកម្ពុជាក្រោម សូមលំអោនកាយគោរពអំពាវនាវយ៉ាងទទូចដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនរួមឈាមទាំងអស់ ព្រះមេត្តា និងមេត្តាជួយឧបត្ថម្ភជាចង្ហាន់ព្រះសង្ឃ ទឹកបរិសុទ្ធ ឬជាថវិកា តាមសទ្ធាជ្រះថ្លាដល់គណៈកម្មការបុណ្យ ដើម្បីយើងខ្ញុំព្រះករុណា យើងខ្ញុំ មានលទ្ធភាពរៀបចំពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន ១៩៤៩អង្គ និង រំលឹកខួបទី ៦៣ឆ្នាំនៃថ្ងៃអាណានិគមបារាំងបានកាត់ទឹកដីខ្មែរកម្ពុជាក្រោមប្រគល់ឲ្យអាណានិគមវៀតណាមបានសម្រេចជោគជ័យតាមការគ្រោងទុក។

ពិធីបុណ្យជាប្រវត្តិសាស្ត្រនេះ ដែលប្រព្រឹត្តទៅបានដោយជោគជ័យ គឺអាស្រ័យដោយការជួយឧបត្ថម្ភគាំទ្រទាំងសម្ភារៈ ថវិកា និងស្មារតីរបស់ព្រះកុណាគ្រប់ព្រះអង្គ និងបងប្អូនរួមឈាមទាំងស្រុង។

សេចក្ដីអំពាវនាវនេះ ចាត់ទុកជាសេចក្ដីនិមន្តនិងអញ្ជើញ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គនិងបងប្អូនជនរួមជាតិ និងសប្បុរសជនទាំងអស់ ព្រះមេត្តា និងមេត្តា និមន្តនិងអញ្ជើញចូលរួមឲ្យបានច្រើនកុះករ ដើម្បីបង្ហាញសហគមន៍អន្តរជាតិឲ្យឃើញពីការឈឺចាប់និងការសោកស្ដាយអាល័យស្រណោះចំពោះការបាត់បង់ទឹកដីដ៏ជាទីស្រឡាញ់របស់យើងទាំងអស់គ្នា ។

ការធ្វើវិភាគទាន ឬការនិមន្តនិងអញ្ជើញចូលរួមរបស់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនរួមជាតិក្នុងពិធីបុណ្យនេះ គឺជាការសម្ដែងនូវការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះព្រះវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធព្រះវីរសមណៈ ព្រះវីរព្រះមហាក្សត្រ និងវីរបុរស-នារី យុទ្ធជន យុទ្ធនារីខ្មែរស្នេហាជាតិ ព្រមទាំងបានជាប្រយោជន៍ដ៏ធំធេងដល់ប្រជារាស្ត្រ និងមាតុភូមិខ្មែរកម្ពុជាក្រោមយ៉ាងពិតប្រាកដ។

កម្មវិធីបុណ្យនឹងប្រព្រឹត្តទៅក្រោមព្រះអធិបតីភាពព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃ**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១២ ចាប់ពីម៉ោង ៧:៣០នាទីព្រឹក រហូតដល់ ម៉ោង ១១:៣០នាទីថ្ងៃត្រង់ នាសួនច្បារ មុខវត្តបទុមវតី រាជធានីភ្នំពេញ (ម៉ោង ៨ព្រឹកចាប់ផ្ដើមប្រារព្ធពិធី) ។

គណៈកម្មការបុណ្យសូមថ្លែងអំណរព្រះគុណ និងអំណរគុណទុកជាមុន ចំពោះស្មារតីស្នេហាជាតិ និងសទ្ធាជ្រះថ្លា របស់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនរួមជាតិ ដែលបានចូលរួមក្នុងពិធីបុណ្យ និងសូមឲ្យបានប្រកបដោយពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

សូមអរព្រះគុណនិងអរគុណ!

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១២

**នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម**

**ថាច់ សេដ្ឋា**
**សមាជិកព្រឹទ្ធសភា**

*សម្រាប់ព្រះករុណា ព្រះថេរានុត្ថេរៈ បងប្អូនជនរួមជាតិ និងសប្បុរសជន គង់និងរស់នៅសហរដ្ឋអាមេរិក ព្រមទាំងនៅបណ្ដាប្រទេសនានា សូមផ្ញើសែករូបិយវត្ថុទៅលោក ថាច់ រ៉ា តាមអាសយដ្ឋាននៅខាងក្រោម៖*

For U.S. residents and other countries, please kindly make payable personal check, traveler's check or money order and send it to:

**RA THACH**
P.O. BOX 37502
PHILADELPHIA, PA 19148
U.S.A.

**---------------------------------------------------**

*សម្រាប់ព្រះករុណា ព្រះថេរានុត្ថេរៈ បងប្អូនជនរួមជាតិ និងសប្បុរសជន គង់និងរស់នៅប្រទេសកាណាដា សូមផ្ញើសែករូបិយវត្ថុទៅលោក គិម សុវង្ស តាមអាសយដ្ឋាននៅខាងក្រោម៖*

For Canada residents, please kindly make payable personal check, traveler's check or money order and send it to:

**SUVONG KIM**
25 GALSWORTHY AVENUE
SCARBOROUGH, ONTARIO M1R 2N5
CANADA

**---------------------------------------------------**

*សម្រាប់ព្រះករុណា ព្រះថេរានុត្ថេរៈ បងប្អូនជនរួមជាតិ និងសប្បុរសជន គង់និងរស់នៅព្រះរាជាណាចក្រកម្ពុជា និងនៅលើទឹកដីកម្ពុជាក្រោម សូមនិមន្តនិងអញ្ជើញទាក់ទងទៅអាសយដ្ឋានខាងក្រោម៖*

For residents of Cambodia and Kampuchea Krom, please kindly contact us at an address below:

The Khmer Kampuchea Krom Community (KKC)
House No. 10B, Street 234, Tuk Laak 3 commune, Tuol Kork district
Phnom Penh, Kingdom of Cambodia
Phones: 011 855 12 908 882 or 011 855 090 477 007; E-mail: thachsetha@gmail.com

**---------------------------------------------------**

*សម្រាប់ព័ត៌មានទូទៅ សូមព្រះករុណា ព្រះថេរានុត្ថេរៈ បងប្អូនជនរួមជាតិ និងសប្បុរសជន និមន្តនិងអញ្ជើញទាក់ទង ទៅតំណាងសហគមន៏តាមរយៈលេខទូរស័ព្ទនិងអាសយដ្ឋានអ៊ីមែលដូចមាននៅខាងក្រោម៖*

General Contact Info:

| | | |
|---|---|---|
| គិម វុឌ្ឍី | Vithi Kim | 864.494.1991 |
| គិម សុវង្ស | Suvong Kim | 647.783.1551 |
| សឺន ស៊ីណា | Sina Son | 267.242.3608 |
| គិម សារេត | Saret Kim | 978.328.4435 |
| វិញ ថន | Thol Vinh | 909.357.3344, 909.576.2192 |
| គិម សកល | Sakal Kim | 617.719.1447 |

For inquiries, please email us at this address: KKCpressoffice@yahoo.com.

សូមអរព្រះគុណ និងសូមអរគុណ។ Thank you for your charity.

www.khmerkromngo.org